ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីពី

# យុទ្ធនាការដាក់អោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺ

# នៅមន្ទីរពេទ្យបង្អែកសៀមរាប

# Report on Launching on SMS Appointment Reminder System for Siem Reap Referral Hospital



ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

09 September 2010

pangaea GLOBAL AIDS FOUNDATION

InSTEDD Innovative Support to Emergencies Diseases and Disasters

# របាយការណ៍ស្តីពី
# យុទ្ធនាការដាក់អោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺ
# នៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប

Report on Launching on SMS Appointment Reminder System for
SIEM REAP Hospital




កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានសហការជាមួយការិយាល័យប្រយុទ្ធនឹងជំងឺអេដស៍នៃមន្ទីរសុខាភិបាលខេត្តសៀមរាប រៀបចំបើកយុទ្ធនាការដាក់អោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺ (SMS Appointment Reminder System) សំរាប់មន្ទីរពេទ្យខេត្តសៀមរាប ។ កម្មវិធីនេះត្រូវបានផ្តួចផ្តើមរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយមានការជួយឧបត្ថម្ភថវិកាពីអង្គការ Pangaea Global AIDS Foundation (PGAF) និងមានជំនួយផ្នែកបច្ចេកទេសពីអង្គការ InSTEDD ក្នុងទិសដៅរំលឹកការណាត់ជួបអ្នកជំងឺក្នុងការមកទទួលការព្យាបាលបន្ត តាមរយៈការផ្ញើសារ SMS ទៅកាន់ទូរស័ព្ទដៃរបស់ក្រុមថែទាំតាមផ្ទះនីមួយៗ ដើម្បីអោយក្រុមថែទាំតាមផ្ទះទាំងអស់បានដឹងពីពេលវេលា សំរាប់ធ្វើការក្រើនរំលឹកដល់អ្នកជំងឺ ដែលត្រូវតែមកទទួលការព្យាបាលបន្តតាមកាលកំណត់របស់គ្រូពេទ្យ ។

សមាសភាពដែលបានចូលរួមក្នុងយុទ្ធនាការដាក់អោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺ សំរាប់មន្ទីរពេទ្យខេត្តសៀមរាប មាន :

**១- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

- ឯកឧត្តមវេជ្ជ. មាន ឈីវុន ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- លោកបណ្ឌិត សាផុន វឌ្ឍនៈ អនុប្រធានវិទ្យាស្ថានស្រាវជ្រាវសុខភាពសាធារណៈ
- លោកវេជ្ជ. លី ពេញស៊ុន អនុប្រធានមជ្ឈមណ្ឌលជាតិ
- លោកវេជ្ជ. មាស វុឌ្ឍី អនុប្រធានមជ្ឈមណ្ឌលជាតិ

- លោក ម៉ម សុវត្ថា ប្រធានផ្នែកគ្រប់គ្រងទិន្នន័យ
- លោកវេជ្ជ. សារុន សារាមុនី មន្ត្រីផ្នែកស្រាវជ្រាវ
- លោកគ្រូពេទ្យ ជា ចំណាន អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យ
- លោក លាង សុផាន់ណា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ

**២- មន្ទីរសុខាភិបាលខេត្តសៀមរាប :**

- លោកវេជ្ជ. អ៊ាប ប៊ុនលឿន អនុប្រធានមន្ទីរសុខាភិបាលខេត្តសៀមរាប
- លោកគ្រូពេទ្យ អឿន សាអែម អនុប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប
- មន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង ចំនួន ០១នាក់
- ក្រុមគ្រូពេទ្យព្យាបាលជំងឺ OI/ART នៃមន្ទីរពេទ្យខេត្តសៀមរាប ចំនួន ១០នាក់
- មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យខេត្តសៀមរាប ចំនួន ០២នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ OI/ART នៃមន្ទីរពេទ្យខេត្តសៀមរាប ចំនួន ០១នាក់
- ក្រុមថែទាំតាមផ្ទះ :
  - តំណាង និងប្រធានក្រុម-ក្រុមថែទាំតាមផ្ទះនៃអង្គការ BFD ចំនួន ០៣នាក់
  - តំណាង និងប្រធានក្រុម-ក្រុមថែទាំតាមផ្ទះនៃអង្គការ SCC ចំនួន ០៣នាក់
  - តំណាង និងប្រធានក្រុម-ក្រុមថែទាំតាមផ្ទះនៃអង្គការ CARITAS ចំនួន ១០នាក់
  - តំណាងអង្គការ KHANA ចំនួន ០២នាក់

បន្ទាប់ពីគោរពភ្លេងជាតិដែលជាកិច្ចចាប់ផ្តើមនៃកម្មវិធីរួចមក លោកវេជ្ជ. អ៊ាប ប៊ុនលឿន អនុប្រធាមន្ទីរសុខាភិបាលខេត្តសៀមរាប បានស្វាគមន៍ចំពោះភ្ញៀវជាតិ និងអន្តរជាតិដែលបានចូលរួម នឹងបានជំរាបជូនដល់ភ្ញៀវទាំងអស់អំពីការងារសុខាភិបាលកន្លងមក ជាពិសេសលើការអនុវត្តន៏ការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ដែលមកដល់ពេលបច្ចុប្បន្ននេះ ខេត្តសៀមរាបមានសេវាទទួលពិនិត្យ និងព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន ០៤កន្លែង, ០៣កន្លែងគ្រប់គ្រងដោយមន្ទីរសុខាភិបាលខេត្ត មានជាអាទិ៍នៅ: មន្ទីរពេទ្យខេត្ត -មន្ទីរពេទ្យបង្អែកសូទ្រនិគម-មន្ទីរពេទ្យបង្អែកក្រឡាញ់ នឹង ០១កន្លែងទៀតគឺ មន្ទីរពេទ្យកុមារអង្គរ ទទួលពិនិត្យ និងព្យាបាលសំរាប់កុមារ ។ ជាមួយគ្នានោះដែរ លោកប្រធានមន្ទីរសុខាភិបាលខេត្ត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុម គ្រូពេទ្យដែលបានយកចិត្តទុកដាក់ក្នុងការពិនិត្យ និងព្យាបាលជូនដល់អ្នកជំងឺ-ក្រុមការងារថែទាំតាមផ្ទះ ដែលយកចិត្តទុកដាក់ក្នុងការតាមដាន និងជំរុញការបញ្ជូនអ្នកជំងឺនៅតាមបណ្តាភូមិអោយមកទទួលសេវានៅមន្ទីរពេទ្យ ជាពិសេសចំពោះមជ្ឈមណ្ឌលជាតិដែលបានប្រឹងប្រែងជួយឧបត្ថម្ភទាំងបច្ចេកទេស នឹងសំភារៈដល់សេវាពិនិត្យ និងព្យាបាលកាន់តែមានប្រសិទ្ធភាព ។

បន្ទាប់ពីមតិស្វាគមន៏របស់លោកប្រធានមន្ទីរសុខាភិបាលខេត្តរួចមក លោកគ្រូពេទ្យ អឿន សាអែម អនុប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប បានធ្វើការបង្ហាញជូនដល់អង្គពិធីទាំងមូលអំពីស្ថានភាពនៃការថែទាំ និងព្យាបាលបន្ត ដល់អ្នកផ្ទុកមេរោគអេដស៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលជារួមមាន:

- តំបន់ប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តន៏ការថែទាំអ្នកជំងឺតាមផ្ទះនៅក្នុងខេត្តសៀមរាប ។
- ស្ថានភាពសេវាសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១០ ក្នុងតំបន់គ្របដណ្តប់ដោយមន្ទីរពេទ្យបង្អែកខេត្ត មានអង្គការ BFD- អង្គការ CARITAS- អង្គការ SCC ។
- ស្ថានភាពអតិថិជនដែលទទួលការធ្វើតេស្តឈាមរកមេរោគអេដស៍ រយៈពេល ០៦ ខែ ក្នុងឆ្នាំ ២០១០ ។

- ស្ថានភាពស្រ្តីមានផ្ទៃពោះដែលទទួលការធ្វើតេស្តឈាមរមមេរោគអេដស៍ រយៈពេល ០៦ ខែ ក្នុងឆ្នាំ ២០១០ ។
- ស្ថានភាពអ្នកផ្ទុកមេរោគអេដស៍ មកទទួលការព្យាបាលនៅមន្ទីរពេទ្យសៀមរាប រយៈពេល ០៦ ខែ ក្នុងឆ្នាំ ២០១០ ។
- ស្ថានភាពអ្នកជំងឺអេដស៍ ដែលមកទទួលការព្យាបាលយឺតជាងថ្ងៃណាត់ជួប
- ស្ថានភាពកុមារផ្ទុកមេរោគអេដស៍មកទទួលការព្យាបាលនៅមន្ទីរពេទ្យបាត់ដំបង រយៈពេល ០៦ ខែ ក្នុងឆ្នាំ ២០១០ ។





បន្ទាប់មក លោកគ្រូពេទ្យ ជា ចំណាន អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ បានធ្វើការបង្ហាញអំពីពត៌មានសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធដល់ការជ្រើសរើសយកប្រព័ន្ធ SMS មកធ្វើការប្រើប្រាស់ក្នុងការរំលឹកដល់អ្នកជំងឺអោយមកទទួលការព្យាបាលបន្ត ដើម្បីៈ

- កុំអោយមានការយឺតយ៉ាវក្នុងការមកទទួលការព្យាបាលបន្ត ចៀសវាងការអស់ថ្នាំលេប
- កុំអោយមានការយឺតយ៉ាវក្នុងការទទួលថ្នាំ ARV នៅពេលដែលអ្នកជំងឺមានលក្ខណៈសមស្រប

ជាមួយគ្នានោះដែរ ក៏បានបង្ហាញនូវលក្ខណៈសំខាន់ៗនៃប្រព័ន្ធ SMS មួយចំនួនទៀតមានជាអាទិ៍ :

- ប្រព័ន្ធ SMS ត្រូវបានភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ដែលមានស្រាប់
- ប្រព័ន្ធ SMS ត្រូវបានរៀបចំសំរាប់ប្រើប្រាស់ជាមួយបណ្តាញទូរស័ព្ទ
- មានតំលៃថោកជាងការនិយាយតាមទូរស័ព្ទ
- ផ្តល់ពត៌មានអំពីស្ថានភាពអ្នកជំងឺ អោយក្រុមថែទាំតាមផ្ទះ នឹងទទួលពត៌មានត្រឡប់ បានទាន់ពេល
- ពត៌មានដែលបញ្ជូនអោយក្រុមថែទាំតាមផ្ទះ មានការបែងចែកទៅតាមប្រភេទនៃការមកជួបគ្រូពេទ្យ
- ជួយដល់អ្នកជំងឺ បានមកជួប នឹងធ្វើការពិនិត្យជាមួយគ្រូពេទ្យបានទៀងទាត់
- បង្កើនទំនាក់ទំនងកាន់តែប្រសើរថែមទៀតរវាងអ្នកផ្តល់សេវាថែទាំ ជាមួយនឹងក្រុមថែទាំតាមផ្ទះ

កម្មវិធីនេះ រៀបចំឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយមានការជួយឧបត្ថម្ភថវិកាដោយអង្គការ Pangaea Global AIDS Foundation (PGAF) នឹងមានជំនួយផ្នែកបច្ចេកទេសដោយអង្គការ InSTEDD ។

សំភារៈសំរាប់ដំណើរការដល់កម្មវិធី មានៈ - ម៉ាស៊ីនកុំព្យូទ័រ ចំនួន ០១គ្រឿង- ទូរស័ព្ទដៃម៉ាក Sony Ericsson ចំនួន ១៣គ្រឿង- Modem ចំនួន ០១ គ្រឿង សំរាប់ប្រព័ន្ធទូរស័ព្ទ និង ថវិកាសំរាប់ដំណើរការផ្ញើសារ ។





បន្ទាប់មកទៀត មានការបង្ហាញដោយលោក លាង សុផាន់ណា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ អំពីពត៌មានដែលត្រូវបញ្ជូនចេញពីម៉ាស៊ីនកុំព្យូទ័រ ទៅតាមទូរស័ព្ទដៃ និងការបង្ហាញអំពីការឆ្លើយតបមកវិញតាមរយៈទូរស័ព្ទដៃ មកម៉ាស៊ីនកុំព្យូទ័រវិញ ។



ការបង្ហាញនេះ មានការប្រើប្រាស់ទូរស័ព្ទដៃជាឧទាហរណ៏ជូនដល់សិក្ខាកាមដែលបានចូលរួមទាំងអស់ ដើម្បីពិនិត្យនឹងបញ្ជាក់ជូនអំពីពណ៌របស់អក្សរដែលជាសារ នៅក្នុងទូរស័ព្ទនៅពេលដែលទទួលបាន ។



បន្ទាប់មកទៀត កញ្ញា ស៊ុយ ចាន់ណេ តំណាងអង្គការ InSTEDD ក៏បានមានមតិចាប់អារម្មណ៍ចំពោះយុទ្ធនាការ ដាក់អោយប្រើប្រាស់ប្រព័ន្ធរំលឹកការណាត់ជួប ដែលជាកម្មវិធីមួយថ្មីសំរាប់សេវាពិនិត្យ និងព្យាបាលអ្នកជំងឺ ហើយក៏បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលជាតិ ដែលបានជ្រើសរើសកម្មវិធីនេះមកដាក់អោយប្រើប្រាស់សាកល្បងជាលើកដំបូង នៅក្នុងប្រទេសកម្ពុជា ជាពិសេសសំរាប់ខេត្តបាត់ដំបង និងខេត្តសៀមរាប ។



មុននឹងប្រារព្ធពិធីបើកអោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺសំរាប់មន្ទីរពេទ្យខេត្តសៀមរាប ឯកឧត្តម វេជ្ជបណ្ឌិត **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានស្វាគមន៍ និង ថ្លែងអំណរគុណចំពោះភ្ញៀវជាតិ-អន្តរជាតិទាំងអស់ដែលបានមកចូលរួមក្នុងពិធីនេះ ។







Launching on SMS Appointment Reminder System for Siem Reap Hospital





ឯកឧត្តមបានមានប្រសាសន៍បញ្ជាក់ជូនអង្គពិធីទាំងមូល អំពីការជ្រើសរើសកម្មវិធីនេះយកមកអនុវត្ត ហើយជាពិសេសដើម្បីអោយកម្មវិធីនេះអាចដំណើរការការងារទៅបាន ត្រូវមានការចូលរួមអនុវត្តដោយ ក្រុមអ្នកផ្តល់សេវាថែទាំអ្នកជំងឺសំរាប់មន្ទីរពេទ្យបង្អែក ដោយមានការចូលរួមសហការពីផ្នែកគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត នឹងក្រុមថែទាំតាមផ្ទះ ក្នុងទិសដៅធ្វើយ៉ាងណាកាត់បន្ថយនូវភាពយឺតយ៉ាវក្នុងការមកទទួលការពិនិត្យ-ព្យាបាលបន្តរបស់អ្នកជំងឺ អោយមានអត្រាទាបបំផុត ។

បន្ទាប់មក ឯកឧត្តម បានប្រកាសបើកអោយប្រើប្រាស់កម្មវិធីរំលឹកការណាត់ជួបអ្នកជំងឺ សំរាប់មន្ទីរពេទ្យបង្អែក សៀមរាប ចាប់ពីពេលនេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

| បានឃើញ និងឯកភាព | បានពិនិត្យ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| **ប្រធានមជ្ឈមណ្ឌលជាតិ** | ជ. ប្រធានផ្នែកគ្រប់គ្រងទិន្នន័យ | |
| វេជ្ជ. មិន ឈីវុន | | លាង សុជាន់ណា |